**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ ០១៩.អបស.មព

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ជម្រាបមក**

**លោក លោកស្រី ប្រធានមន្ទីសុខាភិបាលរាជធានី ខេត្ត-ក្រុង**

**កម្មវត្ថុ:** ករណីផ្តល់សេវាការពារនិងព្យាបាលដល់ទណ្ឌិតនិងពិរុទ្ធជនក្នុងពន្ធនាគារ

**យោង:** លិខិតលេខ ១៣៥/០២ គស-មគ ចុះថ្ងៃទី១៩-០៧-០១ របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

លិខិតលេខ ០០១៨ អបស-មព ចុះថ្ងៃទី១២-០៧-៩៩ របស់ក្រសួងសុខាភិបាល

ន័យដូចចែងក្នុងកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជម្រាបនិងធ្វើសេចក្តីណែនាំដល់លោក-លោកស្រី ដែលជាប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត-ក្រុង ទូទាំងប្រទេសក្នុងការទទួលភារៈកិច្ចផ្តល់សេវាការពារនិងព្យាបាលដល់ទណ្ឌិតនិងពិរុទ្ធជនក្នុងពន្ធនាគារ ដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការផ្តល់សេវាការពារនិងព្យាបាលដល់ទណ្ឌិតនិងពិរុទ្ធជនសូមលោក-លោកស្រី ចាត់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ដែលនៅជិតពន្ធនាគារឱ្យចុះទំនាក់ទំនងដាក់កម្មវិធីសម្រាប់ចុះត្រួតពិនិត្យសុខភាព ដល់ទណ្ឌិតនិងពិរុទ្ធជនហើយធ្វើរបាយការណ៍ស្ថិតិដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានដើម្បីស្នើសុំឱសថ បរិក្ខាពេទ្យ ឱ្យបានទាន់ពេលវេលា ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះសូមលោក-លោកស្រី ទទួលអនុវត្តការងារនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១

**ជ.រដ្ឋមន្ត្រី**

**អនុរដ្ឋលេខាធិការ**

**វេជ្ជ.ជា ឆាយ**

ចម្លងជូន

-ក្រសួងយុត្តិធម៌

-ក្រសួងមហាផ្ទៃ

-ខុទ្ទកាល័យក្រសួងសុខាភិបាល

-អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល

-សាលាខេត្ត-ក្រុង

-កាលប្បវត្តិ - ឯកសារ